# សេចក្តពន្យល់អំពីករណី
# លោក ម៉ម សូណង់ដូ

---

របាយការណ៍សង្ខេប លីកាដូ

ខែសីហា ឆ្នាំ២០១២

សម្ព័ន្ធខ្មែរជំរឿននិងការពារសិទ្ធិមនុស្ស លីកាដូ

**LICADHO**

CAMBODIAN LEAGUE FOR THE PROMOTION
AND DEFENSE OF HUMAN RIGHTS

## សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ

លីកាដូ គឺជាអង្គការសិទ្ធិមនុស្សជាតិមួយនៅកម្ពុជា។ ចាប់តាំងពីអង្គការលីកាដូ ត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៩២ អង្គការនេះ គឺជាអង្គការស្ថិតនៅជួរមុខគេក្នុងកិច្ចការពារសិទ្ធិមនុស្សនៅកម្ពុជា និងលើកស្ទួយការគោរពសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយតាមរយៈរាជរដ្ឋាភិបាលកម្ពុជា និងស្ថាប័ននានា។ ការកសាងសមិទ្ធិផលរបស់ខ្លួនក្នុងអតីតកាល **លីកាដូ** បានបន្តដើរតួជាអ្នកតស៊ូមតិសម្រាប់ប្រជាពលរដ្ឋ និងឃ្លាំមើលរដ្ឋាភិបាលតាមរយៈកម្មវិធីសិទ្ធិមនុស្សនានា ពីការិយាល័យកណ្តាលរបស់ខ្លួននៅភ្នំពេញ និងនៅតាមសាខាទូទាំង១២ ខេត្ត-រាជធានីផ្សេងទៀត។

អង្គការលីកាដូ អនុវត្តសកម្មភាពរបស់ខ្លួនតាមរយៈកម្មវិធីធំៗពីរៈ

### កម្មវិធីឃ្លាំមើល និងការពារសិទ្ធិមនុស្សៈ

- **ឃ្លាំមើលការរំលោភសិទ្ធិមនុស្សដែលប្រព្រឹត្តដោយបុគ្គលរបស់រដ្ឋលើការរំលោភសិទ្ធិស្ត្រី និងការរំលោភសិទ្ធិកុមារៈ** បុគ្គលិកធ្វើការស៊ើបអង្កេតលើករណីរំលោភសិទ្ធិមនុស្សដែលប្រព្រឹត្តដោយបុគ្គលរបស់រដ្ឋ ចំពោះការរំលោភបំពានលើស្ត្រី និងកុមារ ហើយជនរងគ្រោះត្រូវបានផ្តល់សេវាជួយជ្រោមជ្រែងតាមរយៈការធ្វើអន្តរាគមន៍ជាមួយអាជ្ញាធរមូលដ្ឋាន។
- **ការប្រឹក្សាផ្នែកច្បាប់ និងកិច្ចការពារផ្នែកច្បាប់ៈ** ជនរងគ្រោះ ត្រូវបានផ្តល់ជូននូវការប្រឹក្សាផ្នែកច្បាប់ ហើយចំពោះករណីសំខាន់ៗ ទទួលបាននូវកិច្ចការពារផ្នែកច្បាប់ដែលផ្តល់ជូនដោយក្រុមប្រឹក្សាផ្នែកច្បាប់ និងក្រុមមេធាវីការពារសិទ្ធិមនុស្ស។
- **ការឃ្លាំមើលពន្ធនាគារៈ** អ្នកស្រាវជ្រាវពន្ធនាគារធ្វើការឃ្លាំមើលពន្ធនាគារចំនួន១៨ ដើម្បីធ្វើការវាយតម្លៃអំពីស្ថានភាពនៅក្នុងពន្ធនាគារ និងដើម្បីធានាថាជនជាប់ឃុំទទួលបាននូវតំណាងផ្នែកច្បាប់។
- **ជំនួយផ្នែកវេជ្ជសាស្ត្រៈ** ក្រុមគ្រូពេទ្យផ្តល់សេវាវេជ្ជសាស្ត្រដល់ជនជាប់ឃុំ និងមន្ត្រីពន្ធនាគារចំនួន១២ កន្លែង។ បន្ថែមពីលើនេះ ក៏ជួយផ្តល់សេវាវេជ្ជសាស្ត្រ និងបញ្ជូនជនរងគ្រោះដោយការរំលោភសិទ្ធិមនុស្សទៅកាន់មន្ទីរពេទ្យ។

- **សេវាកម្មសង្គមកិច្ច:** ក្រុមការងារធ្វើការវាយតម្លៃពីតម្រូវការរបស់ជនរងគ្រោះ និងក្រុមគ្រួសាររបស់ពួកគេ ហើយផ្តល់ជំនួយសម្ភារៈ និងម្ហូបអាហាររយៈពេលខ្លី។

**កម្មវិធីទំនាក់ទំនង និងការទាក់ទាញមតិគាំទ្រ:**

- **ការហ្វឹកហ្វឺនសហគមន៍ អប់រំ និងការតស៊ូមតិ:** អ្នកហ្វឹកហ្វឺន និងអ្នកតស៊ូមតិធ្វើការអប់រំដល់សាធារណជនអំពីសិទ្ធិស្ត្រី និងសិទ្ធិកុមារបង្កើតបណ្តាញការពារនៅតាមមូលដ្ឋាន និងធ្វើការតស៊ូមតិដើម្បីឲ្យមានការផ្លាស់ប្តូរសង្គម និងគោរពច្បាប់។
- **ការតស៊ូមតិជាសាធារណៈ និងតាមសហគមន៍:** ករណីរំលោភសិទ្ធិមនុស្សដែលស៊ើបអង្កេតដោយលីកាដូ ត្រូវបានចងក្រងទុកនៅក្នុងប្រព័ន្ធទិន្នន័យ ដើម្បីឲ្យមានភាពងាយស្រួលក្នុងការស្វែងរកព័ត៌មាន វិភាគ ផលិតជារបាយការណ៍ជាប្រចាំ (ការបោះពុម្ពជារបាយការណ៍ និងរបាយការណ៍សោតទស្សន៍)។

**ចំពោះព័ត៌មានបន្ថែមសូមទាក់ទង:**

លោកស្រីវេជ្ជបណ្ឌិត ពុង ឈីវកេក ប្រធានអង្គការលីកាដូ

អាសយដ្ឋាន: អង្គការលីកាដូ (សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស)

ផ្ទះលេខ ១៦ ផ្លូវលេខ ៩៩ រាជធានីភ្នំពេញ កម្ពុជា

ទូរស័ព្ទ: (+៨៥៥) ២៣ ៧២៧ ១០២/២១៦ ៦០២ ទូរសារ: (+៨៥៥) ២៣ ៧២៧ ១០២/២១៧ ៦២៦

អ៊ីម៉ែល: contact@licadho-cambodia.org

គេហទំព័រ: http://www.licadho-cambodia.org

# មាតិកា


ទស្សនៈរួម........................................................................ ២

ព្រឹត្តការណ៍កន្លងមក........................................................ ២

បទចោទ..........................................................................................២

អនុសាសន៍នានា ................................................................................២


□□□

# ទស្សនៈរួម

នៅព្រឹកថ្ងៃអាទិត្យទី១៥ ខែកក្កដាឆ្នាំ ២០១២ លោក ម៉ម សូណង់ដូ ដែលជាម្ចាស់ និងជានាយកស្ថានីយវិទ្យុសំបុកឃ្មុំឯករាជ្យ ត្រូវបានចាប់ខ្លួននៅឯស្ថានីយវិទ្យុរបស់លោក។ លោក ម៉ម សូណង់ដូ អាយុ ៧០ ឆ្នាំមានសញ្ជាតិពីរ គឺសញ្ជាតិបារាំង និងសញ្ជាតិខ្មែរ។ គាត់ជាអ្នកបង្កើត និងជាប្រធានសមាគមអ្នកប្រជាធិបតេយ្យផងដែរ ជាអង្គការមិនមែនរដ្ឋាភិបាលមួយបានចុះបញ្ជីយ៉ាងត្រឹមត្រូវ ដែលមានគោលដៅលើកស្ទួយសិទ្ធិមនុស្ស និងលទ្ធិប្រជាធិបតេយ្យនៅប្រទេសកម្ពុជា (ជាពិសេសតាមរយៈការធានាការធ្វើ នូវអត្តសញ្ញាណប័ណ្ណខ្មែរ ដើម្បីសម្រួលលទ្ធភាព ឲ្យកាន់តែងាយស្រួលក្នុងការ បោះឆ្នោត)។



*លោក ម៉ម សូណង់ដូ ត្រូវបានទទួលអបអរសាទរពីអ្នកគាំទ្រ និងអ្នកសារព័ត៌មាននៅព្រលានយន្តហោះរាជធានីភ្នំពេញបន្ទាប់ពីវិលត្រឡប់ពីបរទេសវិញ ចំនួន ៣ ថ្ងៃមុនពេលចាប់ខ្លួន។*

បន្ទាប់ពីបានឃាត់ខ្លួននៅក្នុងអង្គភាពនគរបាលអស់រយៈពេលមួយយប់មក លោក ម៉ម សូណង់ដូ ត្រូវបានគេនាំមកបង្ហាញខ្លួននៅចំពោះមុខអ្នកស្រី សែម សក្តិកូឡា ជាចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ដើម្បីធ្វើការសាកសួរយកចម្លើយ។ នៅវេលាប្រហែលថ្ងៃត្រង់ទី១៦ ខែកក្កដា លោក ម៉ម សូណង់ដូ ត្រូវបានចោទប្រកាន់ ដោយព្រះរាជអាជ្ញាតាមមាត្រាចំនួនប្រាំមួយនៃក្រមព្រហ្មទណ្ឌកម្ពុជា។ លោក ម៉ម សូណង់ដូ ត្រូវបានចោទប្រកាន់ពីបទដឹកនាំចលនាអបគមន៍ និងញុះញង់ប្រជាពលរដ្ឋឲ្យកាន់អាវុធប្រឆាំងនឹងរដ្ឋរហូតដល់បទល្មើសប្រឆាំងមន្ត្រីសាធារណៈ។ ប្រសិនបើគាត់ត្រូវបានគេកាត់ទោសឲ្យជាប់ពិរុទ្ធនៅគ្រប់បទចោទប្រកាន់ទាំងអស់ លោក ម៉ម សូណង់ដូនឹងត្រូវប្រឈមមុខនឹងការដាក់ឲ្យជាប់ពន្ធនាគារចំនួនពី ៧ ទៅ ៣០ ឆ្នាំ។

រដ្ឋាភិបាលអះអាងថា បទចោទប្រកាន់ប្រឆាំងនឹងលោក ម៉ម សូណង់ដូ មានការពាក់ព័ន្ធទៅនឹងការប៉ុនប៉ងធ្វើអបគមន៍ពីសំណាក់អ្នកភូមិរស់នៅក្នុងខេត្តក្រចេះ។ អ្នកភូមិទាំងនោះដែលត្រូវបានចោទប្រកាន់ពីបទប៉ុនប៉ងធ្វើអបគមន៍ បានពាក់ព័ន្ធក្នុងជម្លោះដីធ្លីមួយដែលកំពុងតែបន្តកើតមាន និងមានលក្ខណៈកាន់តែធ្ងន់ធ្ងរឡើង ជាមួយក្រុមហ៊ុន

ឯកជនមួយនៅឃុំដំរីស្រុកឆ្លូង ដែលមានជាប់ពាក់ព័ន្ធនឹងអ្នកមានអំណាច។ នៅថ្ងៃទី១៦ ខែឧសភាឆ្នាំ ២០១២ នៅពេលដែលលោក ម៉ម សូណង់ដូ នៅក្រៅប្រទេស មានកងកម្លាំងចម្រុះទាហាន កងរាជអាវុធហត្ថ និងនគរបាលមូលដ្ឋានចំនួនរាប់រយនាក់ បានសម្រុកចូលទៅកាន់ដីមានទំនាស់ ដោយមានឧទ្ធម្ភាគចក្រមួយគ្រឿងជាជំនួយ។ អ្នកភូមិរាប់រយគ្រួសារត្រូវបានបង្ខំឲ្យចាក់ចេញពីដីធ្លីនោះ។ នៅពេលកំពុងធ្វើប្រតិបត្តិការបង្ក្រាប ក្មេងស្រីម្នាក់អាយុ ១៤ ឆ្នាំ ត្រូវបានបាញ់សម្លាប់។ នៅថ្ងៃបណ្តេញអ្នកភូមិចេញនោះ អាជ្ញាធរបានរាំងអ្នកសារព័ត៌មាន អង្គការមិនមែនរដ្ឋាភិបាល និងអង្គការសហប្រជាជាតិមិនឲ្យចូលទៅកាន់កន្លែងកើតហេតុ ហើយលើកលែងតែការចុះទៅធ្វើទស្សកិច្ចមួយពីសំណាក់មន្ត្រីអង្គការសហប្រជាជាតិមួយចំនួន ដែលត្រូវបានអមដំណើរការពារសន្តិសុខពីមន្ត្រីនគរបាលជាន់ខ្ពស់ ការបិទផ្លូវបានបន្តធ្វើជាច្រើនថ្ងៃក្រោយមក។[១]

មនុស្សភាគច្រើនបានរិះគន់អំពីការចោទប្រកាន់ពី "ចលនាអបគមន៍" ដើម្បីប្រើប្រាស់កងទាហានក្នុងប្រតិបត្តិការបង្ក្រាបកាលពីថ្ងៃទី១៦ ខែឧសភា ឲ្យស្របច្បាប់។ គ្មានកងកម្លាំងប្រដាប់អាវុធណាម្នាក់ទទួលរងរបួសឡើយ ហើយនៅតែមិនទាន់មានភស្តុតាងត្រូវបានបង្ហាញថាអ្នកស្រុករស់នៅក្នុងតំបន់នោះបានកាន់អាវុធប្រឆាំងនឹងអាជ្ញាធរឡើយ។ ហើយក៏គ្មានភស្តុតាងណាមួយ ដែលថាអ្នកស្រុកមានចេតនា ផែនការណ៍ ឬមធ្យោបាយដើម្បីធ្វើអបគមន៍ដែរចេញពីប្រទេសកម្ពុជា។ ហើយក្រៅពីហេតុការណ៍ ដែលថាអ្នកស្រុកមួយចំនួន បានធ្លាប់ចូលរួមក្នុងសមាគមន៍អ្នកប្រជាធិបតេយ្យ គឺគ្មានតម្រុយចង្អុលបង្ហាញថាសេចក្តីថ្លែងការរបស់អង្គការមិនមែនរដ្ឋាភិបាល ឬរបាយការណ៍ទាំងឡាយ ដែលត្រូវបានផ្សព្វផ្សាយតាមវិទ្យុសំបុកឃ្មុំ មានការលើកឡើងអំពីកិច្ចខិតខំប្រឹងប្រែងប៉ុនប៉ងធ្វើអបគមន៍នៅក្នុងប្រទេសកម្ពុជានោះទេ។

អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ ព្រមទាំងសមាគមអ្នកសារព័ត៌មានផងចាប់ពីពេលនោះមកបានធ្វើសេចក្តីថ្លែងការថា បទចោទប្រកាន់ទាំងឡាយទៅលើលោក ម៉ម សូណង់ដូ ប្រហែលជាមានការពាក់ព័ន្ធច្រើនជាងទៅនឹងប្រវត្តិដ៏យូរអង្វែងនៃការធ្វើសេចក្តីរាយការណ៍រិះគន់ និងដោយឯករាជ្យរបស់វិទ្យុសំបុកឃ្មុំ។

---

[១] មានការចោទប្រកាន់ពីការរំលោភបំពានជាច្រើនផ្សេងទៀត ដែលត្រូវបានប្រព្រឹត្ត ដោយអាជ្ញាធរនៅអំឡុងធ្វើការបណ្តេញចេញ ដោយហិង្សាត្រូវបានរាយការណ៍ឲ្យដឹងចាប់តាំងពីពេលធ្វើប្រតិបត្តិការបង្ក្រប។ ទោះបីយ៉ាងណាក៏ដោយ ដោយសារតែមានការបិទផ្លូវ វាមានការលំបាកក្នុងការផ្ទៀងផ្ទាត់របាយការណ៍ទាំងនេះ។

នៅថ្ងៃទី២៥ ខែមិថុនា ស្ថានីយវិទ្យុនេះបានចាក់ផ្សាយនូវរបាយការណ៍មួយពិពណ៌នាអំពីពាក្យបណ្តឹងមួយ ដែលត្រូវបានដាក់ជូនតុលាការព្រហ្មទណ្ឌអន្តរជាតិ ដោយចោទប្រកាន់មន្ត្រីកម្ពុជាពីបទប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ទាក់ទងនឹងបន្លាស់ទី និងការបណ្តេញចេញដោយបង្ខំ។ នៅថ្ងៃបន្ទាប់មក សម្តេចនាយករដ្ឋមន្ត្រី លោកបានអំពាវនាវឲ្យមានការចាប់ខ្លួនលោក ម៉ម សូណង់ដូ នៅអំឡុងពេលថ្លែងសុន្ទរកថាមួយដែលត្រូវបានចាក់ផ្សាយទូទាំងប្រទេសតាមទូរទស្សន៍ ដែលនៅពេលនោះ សម្តេចនាយករដ្ឋមន្ត្រី លោកបានភ្ជាប់មេដឹកនាំសមាគមអ្នកប្រជាធិបតេយ្យទៅនឹងព្រឹត្តិការណ៍ទាំងឡាយនៅខេត្តក្រចេះ។

ការប៉ុនប៉ងទាំងឡាយ ដើម្បីភ្ជាប់លោក ម៉ម សូណង់ដូ ទៅនឹង "ចលនាអបគមន៍" មួយនេះ ត្រូវបានគេរិះគន់ថា ជាលេសមួយសម្រាប់បំបិទសម្លេងវិទ្យុសំបុកឃ្មុំ ដោយដាក់ម្ចាស់វិទ្យុនេះ និងអ្នកស្វែងរកថវិកាឲ្យជាប់ពន្ធនាគារ។ ដោយសារប្រទេសកម្ពុជាត្រៀមខ្លួនសំរាប់ការបោះឆ្នោតជាតិរបស់ខ្លួនខាងមុខ វិទ្យុសំបុកឃ្មុំគឺជាប្រភពដ៏សំខាន់មួយសំរាប់ផ្សព្វផ្សាយព័ត៌មាន និងការធ្វើអត្ថាធិប្បាយនៅក្នុងប្រទេសកម្ពុជាដោយឯករាជ្យ ដែលត្រូវតែទទួលបាននូវការការពារ។ លទ្ធិប្រជាធិបតេយ្យនឹងលែងមានដំណើរការពេញលក្ខណៈច្បាប់ ប្រសិនបើអ្នកសារព័ត៌មាននិងប្រព័ន្ធផ្សព្វផ្សាយពត៌មាន ត្រូវទទួលរងការគំរាមកំហែងពីការដាក់ទណ្ឌកម្មខាងព្រហ្មទណ្ឌ ដោយសារតែពួកគេប្រើប្រាស់សិទ្ធិជាមូលដ្ឋាន ក្នុងការបញ្ចេញមតិយោបល់របស់ពួកគេ។

# ព្រឹត្តការណ៍កន្លងមក

នៅថ្ងៃទី២២ ខែមិថុនា ឆ្នាំ ២០១២ តំណាងនានាមកពីចលនាអំណាចប្រជាពលរដ្ឋខ្មែរដឹកនាំដោយលោក សួន សេរីរដ្ឋា ដែលជាអ្នករិះគន់រដ្ឋាភិបាល បានធ្វើដំណើរទៅកាន់ទីក្រុងឡាអេ (Hague) ប្រទេសហូឡង់ដ៍។ នៅទីនោះ អ្នកទាំងនោះបានរៀបចំព្រឹត្តិការណ៍សារព័ត៌មានមួយ ដោយធ្វើការផ្សព្វផ្សាយអំពីការទទួលយកពាក្យបណ្តឹងរបស់អ្នកទាំងនោះ ដោយតុលាការព្រហ្មទណ្ឌអន្តរជាតិ ដែលចោទប្រកាន់ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទាក់ទងនឹងជម្លោះដីធ្លីនៅប្រទេសកម្ពុជា។ លោក ម៉ម សូណង់ដូ បានទៅយកព័ត៌មានអំពីព្រឹត្តិការណ៍នេះ នៅឯតុលាការព្រហ្មទណ្ឌអន្តរជាតិនេះ ក្នុងនាមជាអ្នកសារព័ត៌មាន។ វិទ្យុសំបុកឃ្មុំបានធ្វើការចាក់ផ្សាយនៅថ្ងៃទី២៥ ខែមិថុនាឆ្នាំ ២០១២[២] នូវរបាយការណ៍របស់លោក ម៉ម សូណង់ដូ ស្តីពីព្រឹត្តិការណ៍តុលាការព្រហ្មទណ្ឌអន្តរជាតិនេះ។

ម្ភៃបួនម៉ោង (២៤) បន្ទាប់ពីរបាយការណ៍ ស្តីពីព្រឹត្តិការណ៍តុលាការព្រហ្មទណ្ឌអន្តរជាតិនេះ បានចាក់ផ្សាយលើកដំបូង សម្តេចនាយករដ្ឋមន្ត្រី លោកបានអំពាវនាវជាសាធារណៈ ដើម្បីឲ្យធ្វើការចាប់ខ្លួនមេដឹកនាំសមាគមអ្នកប្រជាធិបតេយ្យនៅអំឡុងពេលថ្លែងសុន្ទរកថាមួយនៅរាជធានីភ្នំពេញ ដែលត្រូវបានចាក់ផ្សាយតាមទូរទស្សន៍ជាតិ។ ប្រធានអង្គការមិនមែនរដ្ឋាភិបាលមួយនេះ ត្រូវបានចោទប្រកាន់ពីបទ ដែលគេហៅថាញុះញង់ឲ្យមានការប៉ុនប៉ងធ្វើអបគមន៍នៅខេត្តក្រចេះ ដែលជាការអះអាងតម្រូវឲ្យមានអន្តរាគមន៍ខាងយោធាកាលពីថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១២។ ប្រភេទនៃការចោទប្រកាន់ពីបទ "កុប្បកម្ម" ឬ "អបគមន៍" ពីសំណាក់រដ្ឋាភិបាលទៅលើអ្នកស្រុករស់នៅក្នុងឃុំកំពង់ដំរីបានលេចឡើងស្ទើរតែភ្លាមៗនៅចំពេល ដែលមានការថ្កោលទោសយ៉ាងរាលដាលទៅលើការបណ្តេញចេញដោយហិង្សា ដែលបណ្តាលឲ្យស្លាប់ក្មេងស្រីម្នាក់ឈ្មោះហេង ចន្ថា។

យ៉ាងតិចណាស់ចាប់តាំងពីខែមករាឆ្នាំនេះ អ្នកស្រុកឃុំកំពង់ដំរីជាប់ពាក់ព័ន្ធជាមួយក្រុមហ៊ុនកាសូទីម (Casotim) ទៅលើជម្លោះដីធ្លីមួយ ដែលត្រូវបានផ្សព្វផ្សាយយ៉ាងទូលំទូលាយ។ ក្រុមហ៊ុនមួយនេះ ជាក្រុមហ៊ុនមួយ ទទួលបានដីសម្បទានចំនួន ១៥,០០០

[២] លោក ម៉ម សូណង់ដូ បានចាកចេញពីប្រទេសកម្ពុជានៅខែមីនា ឆ្នាំ២០១២ ហើយលោកបានស្នាក់នៅក្រៅប្រទេសរហូតដល់ពេល ដែលលោកវិលត្រឡប់មកកាន់ប្រទេសកម្ពុជាវិញនៅថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១២។

ហិកតានៅជិតភូមិរបស់ពួកគេ។ អ្នកភូមិដែលមានជំនាស់ដីធ្លីនេះ រាយការណ៍ឲ្យដឹងថា បុគ្គលិកក្រុមហ៊ុនបានប្រាប់ពួកគេឲ្យឈប់ដាំដំណាំ ហើយយ៉ាងតិចណាស់មានមេដឹកនាំសហគមន៍ម្នាក់ (ដែលឈ្មោះ ប៊ុន រដ្ឋា) ក្នុងចំណោមមេដឹកនាំទាំងឡាយ ដែលត្រូវបានចោទប្រកាន់ និងត្រូវបានចាប់ខ្លួនពីបទបំផ្លិចបំផ្លាញទ្រព្យសម្បត្តិឯកជនទាក់ទងនឹងការព្យាយាមការពារបណ្តឹងតវ៉ាដីធ្លីរបស់សហគមន៍។[៣]

## បទចោទ

អ្នកស្រុកឃុំកំពង់ដំរីបានថ្លែងឲ្យដឹងផងដែរថា ក្រុមហ៊ុនកាសូទីមមិនដែលបានបង្ហាញឯកសារឲ្យពួកគេបានឃើញ ដែលបញ្ជាក់ថាដីទំនាស់នេះ ជាផ្នែកនៃដីសម្បទានរបស់ក្រុមហ៊ុនឡើយ។ តាមការពិតកំណត់ហេតុទាំងឡាយ ដែលមានជាសាធារណៈថ្មីៗបំផុតនោះបង្ហាញថា ព្រំដីសម្បទានក្រុមហ៊ុនកាសូទីម គឺមានចម្ងាយពីភូមិរបស់ពួកគេជាង ១៥ គីឡូម៉ែត្រ។

ទោះបីយ៉ាងណាក៏ដោយតាមរយៈសុទ្ធរកថារបស់សម្តេចនាយករដ្ឋមន្ត្រី លោកបានថ្លែងថា អ្នកភូមិមួយចំនួន ដែលត្រូវចោទពីបទចូលរួមក្នុងចលនាអបគមន៍បាន "ឆ្លើយសារភាព" ហើយថាមេដឹកនាំសមាគមអ្នកប្រជាធិបតេយ្យមានការជាប់ជំពាក់ទាក់ទិន។ សម្តេចនាយករដ្ឋមន្ត្រី បន្ទាប់មកលោកបានថ្លែងបន្តទៀតថា បុគ្គលផ្សេងៗទៀត ដែលតុលាការនៅខេត្តក្រចេះកំពុងស្វែងរកចាប់ខ្លួននឹងត្រូវលើកលែងទោស ប្រសិនបើអ្នកទាំងនោះចេញមកសារភាព ហើយនឹងឆ្លើយថា ប្រធានអង្គការមិនមែនរដ្ឋាភិបាលនេះ មានការជាប់ជំពាក់ទាក់ទិនផងនោះ។

នៅថ្ងៃទី២ ខែកក្កដា លោក ចុក ងួន ចៅក្រមស៊ើបសួរបានចេញដីកាចាប់ខ្លួនលោក ម៉ម សូណង់ដូ ដោយចោទប្រកាន់លោកពីបទល្មើសផ្សេងៗទាក់ទងនឹងការញុះញង់ឲ្យមានចលនាកុប្បកម្មមួយនៅខេត្តក្រចេះ។

[៣] លោកប៊ុន រដ្ឋា ត្រូវបានចាប់ខ្លួនពីថ្ងៃទី៦ ខែមេសា ឆ្នាំ២០១២ ហើយដោះលែងវិញនៅថ្ងៃទី៩ ខែមេសា ឆ្នាំ២០១២

នៅថ្ងៃទី១៦ ខែ នៅសាលាដំបូងរាជធានីភ្នំពេញ[៤] លោក ម៉ម សូណង់ដូ ត្រូវបានចោទប្រកាន់ ពីបទល្មើសផ្សេងៗតាមមាត្រា ២៨, ៤៥៦, ៤៥៧, ៤៦៤, ៥០៤ និងមាត្រា ៦០៩ នៃក្រមព្រហ្មទណ្ឌដូចខាងក្រោម:

- មាត្រា៤៥៦ និងមាត្រា៤៥៧ មានចែងអំពីបទល្មើសដឹកនាំ "ចលនាកុប្បកម្ម" មួយ ដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៧ ឆ្នាំទៅ ១៥ឆ្នាំ។
- មាត្រា៤៦៤ ចែងថាជនណា ដែលមានពិរុទ្ធភាពពីបទ "ញុះញង់ឲ្យប្រជាពលរដ្ឋកាន់អាវុធប្រឆាំងនឹងអាជ្ញាធររដ្ឋ" ត្រូវប្រឈមនឹងការផ្តន្ទាទោសដាក់ពន្ធនាគារពី ២ឆ្នាំ ទៅ ៥ ឆ្នាំ និងពិន័យជាប្រាក់។ កាលបើការញុះញង់នេះ បានសម្រេចផលបទល្មើសត្រូវផ្តន្ទាទោសដាក់ ពន្ធនាគារពី ១៥ ឆ្នាំទៅ ៣០ឆ្នាំ។
- មាត្រា៥០៤ ចែងថាការប្រឆាំងនឹងអ្នករាជការសាធារណៈ ដោយមានស្ថានទម្ងន់ទោស ត្រូវផ្តន្ទាទោសដាក់ពន្ធនាគាររហូតដល់ ១ ឆ្នាំ និងពិន័យជាប្រាក់។
- មាត្រា ៦០៩ មានចែងអំពីបទល្មើសជ្រៀតជ្រែកដោយខុសច្បាប់ ទៅក្នុងការបំពេញមុខងារសារធារណៈ ហើយត្រូវផ្តន្ទាទោស ដាក់ពន្ធនាគាររហូតដល់ ៣ ឆ្នាំ និងពិន័យជាប្រាក់។
- មាត្រា ២៨ មានចែងអំពីទ្រឹស្តីទទួលខុសត្រូវសម្រាប់ការផ្តើមគំនិតក្នុងបទព្រហ្មទណ្ឌ ដែលបុគ្គលត្រូវតែទទួលរងការចោទប្រកាន់ពីបទល្មើស ដែលខ្លួនមិនបានប្រព្រឹត្តដោយផ្ទាល់។ វាដូចគ្នាទៅនឹងការទទួលខុសត្រូវរបស់អ្នកសមគំនិត ឬអ្នករួមគំនិត។ អ្នកផ្តើមគំនិតត្រូវប្រឈមនឹងការផ្តន្ទាទោសដូចគ្នាទៅនឹងចារីនៃបទល្មើសដែរ។

ប្រសិនបើលោក ម៉ម សូណង់ដូ ត្រូវបានគេរកឃើញថាមានពិរុទ្ធភាពពីបទចោទប្រកាន់ផ្សេងៗទាំងអស់នេះ ហើយនឹងត្រូវផ្តន្ទាទោសដោយស្រុបទោស គាត់នឹងត្រូវជាប់ពន្ធនាគាររហូត ដល់ទៅ ៣០ឆ្នាំ។[៥]

---

[៤] សំណុំរឿងនេះ ត្រូវបានផ្ទេរពីសាលាដំបូងខេត្តក្រចេះ មកសាលាដំបូងរាជធានីភ្នំពេញ នៅអំឡុងពាក់កណ្តាលខែកក្កដា។

[៥] តាមមាត្រា ១៣៧ នៃក្រមព្រហ្មទណ្ឌ ព្រះរាជអាជ្ញាមានសក្តានុពលអាចព្យាយាមចោទប្រកាន់ដោយបូក ជាជាងស្រុបទោស។ ការព្យាយាមបែបនេះ មិនអាចទៅរួចទេ។ បើទុកជាករណីនេះ ត្រូវចាត់ការក៏ដោយ ក៏យ៉ាងហោចណាស់ ការចោទប្រកាន់ពីបទល្មើសច្រើននឹងគួរតែត្រូវចាត់ទុកដូចគ្នាតាមច្បាប់នេះ ដោយតម្រូវឲ្យមានការកាត់ទោសស្រុប។



អ្នកគាំទ្រយ៉ាងច្រើនជួបជុំគ្នា ដើម្បីអបអរសាទរលោក ម៉ម សូណង់ដូ នៅព្រលានយន្តហោះ

លោក ម៉ម សូណង់ដូ បានចេញក្រៅប្រទេសនៅពេលលោក ចុក ង្វន ជាចៅក្រមស៊ើបសួរសាលាដំបូងខេត្តក្រចេះ បានចេញដីកាចាប់ខ្លួនលោក។ លោក ម៉ម សូណង់ដូ បានអញ្ជើញវិលត្រឡប់មកដល់រាជធានីភ្នំពេញវិញនៅថ្ងៃទី១២ ខែកក្កដា វេលាម៉ោងប្រហែល ១០:១៥នាទីយប់ នៅអំឡុងពេលបញ្ចប់កិច្ចប្រជុំកំពូលអាស៊ាន។ ការចាប់ខ្លួន លោក ម៉ម សូណង់ដូ ក្នុងរយៈពេល ៣ ថ្ងៃក្រោយមក គឺកើតឡើងបន្ទាប់ពីរដ្ឋមន្ត្រីការបរទេស និងអ្នកការទូតមកពីបណ្ដាប្រទេសក្នុងពិភពលោកបានចាកចេញផុតពីរាជធានីភ្នំពេញរាប់ទាំងអ្នកស្រី Hillary Clinton ជារដ្ឋមន្ត្រីការបរទេសអាមេរិកព្រមទាំងអ្នកស្រី Catherine Ashton ជាតំណាងជាន់ខ្ពស់នៃសហភាពអឺរ៉ុបទទួលបន្ទុកកិច្ចការបរទេស។

ថ្វីបើមានហេតុការណ៍ដែលថាលោក ម៉ម សូណង់ដូ បានវិលត្រឡប់មកដល់ប្រទេសកម្ពុជាវិញ ដើម្បីមកប្រឈមនឹងការចោទប្រកាន់ទៅលើរូបលោក ហើយនឹងគ្មានភស្តុតាងត្រូវបានបង្ហាញ ដើម្បីគាំទ្រដល់ការចោទប្រកាន់ទាំងនេះ ក៏ដោយក៏ការស្នើសុំឲ្យដោះលែងនៅក្រៅឃុំបណ្ដោះអាសន្នរង់ចាំការជំនុំជម្រះក្ដី ត្រូវបានចៅក្រមស៊ើបសួរច្រានចោលចំនួនពីរលើករួចមកហើយ។ លោក ម៉ម សូណង់ដូ បច្ចុប្បន្នកំពុងត្រូវបានឃុំខ្លួនបណ្ដោះអាសន្នក្នុងមណ្ឌលអប់រំកែប្រែទី១ ដែលមានភាពចង្អៀតណែននៅព្រៃសក្នុងរាជធានីភ្នំពេញ។ មានការបារម្ភយ៉ាងច្រើនពីសុខភាពរបស់គាត់។

## លោក ម៉ម សូណង់ដូ ត្រូវបានឃុំខ្លួនក្នុងពន្ធនាគារតាមទំនើងចិត្តពីអតីតកាល

នេះមិនមែនជាលើកទីមួយទេ ដែលលោក ម៉ម សូណង់ដូ ត្រូវបានចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ ក្រោយពីមានការចាក់ផ្សាយព័ត៌មានតាមវិទ្យុសំបុកឃ្មុំ។ នៅថ្ងៃទី ៣១ ខែមករាឆ្នាំ ២០០៣ ជាច្រើនខែមុនពេលបោះឆ្នោតជាតិអាណត្តិទីបីនៅប្រទេសកម្ពុជា តុលាការក្រុងភ្នំពេញបានចោទប្រកាន់លោក ម៉ម សូណង់ដូ ពីបទផ្សព្វផ្សាយព័ត៌មានមិនពិត ញុះញង់ឲ្យប្រជាពលរដ្ឋរើសអើង និងញុះញង់ឲ្យប្រជាពលរដ្ឋប្រព្រឹត្តបទល្មើស។ ការចោទប្រកាន់ទាំងនេះ ត្រូវបានធ្វើឡើងបន្ទាប់ពីវិទ្យុសំបុកឃ្មុំបានចាក់ផ្សាយការហៅចូល

តាមទូរស័ព្ទពីអ្នកស្តាប់វិទ្យុនេះធ មួយរូប ដែលគាត់បានចោទប្រកាន់សមាជិកគ្រួសាររាជវង្សថៃមួយអង្គពីបទធ្វើអត្ថាធិប្បាយអុជអាល ដែលនៅអំឡុងពេលនោះ មានកុប្បកម្មប្រឆាំងនឹងជនជាតិថៃជាច្រើន បានកើតឡើងនៅក្នុងទីក្រុងភ្នំពេញ។ នៅពេលនោះ លោក ម៉ម សូណង់ដូ ត្រូវបានគេដោះលែងឲ្យមានសេរីភាពឡើងវិញ បន្ទាប់ពីត្រូវបានឃុំខ្លួនអស់រយៈពេល ២ សប្តាហ៍។

លោក ម៉ម សូណង់ដូ ត្រូវបានចាប់ខ្លួនម្តងទៀតនៅថ្ងៃទី១១ ខែតុលា ឆ្នាំ២០០៥ ហើយបន្ទាប់មក ត្រូវបានចោទប្រកាន់ពីបទបរិហារកេរ្តិ៍ ញុះញង់ និងផ្សាយព័ត៌មានមិនពិត។ បទចោទប្រកាន់ទាំងនោះ គឺមានការទាក់ទង ទៅនឹងការចាក់ផ្សាយតាមវិទ្យុសំបុកឃ្មុំ នូវបទសម្ភាសន៍មួយជាមួយអ្នកជំនាញឯករាជ្យមួយរូប ស្តីអំពីបញ្ហានយោបាយ។ បន្ទាប់ពីមានការចោទប្រកាន់ទាំងអស់នោះ ក្នុងឆ្នាំ២០០៥ លោក ម៉ម សូណង់ដូ បានត្រូវឃុំខ្លួនក្នុងពន្ធនាគារអស់រយៈពេល ៣ខែ មុនពេលដោះលែងឲ្យមានសេរីភាពឡើងវិញឲ្យនៅក្រៅឃុំបណ្តោះអាសន្នរង់ចាំបើកសវនាការខែមករា ឆ្នាំ២០០៦។ ការដោះលែងនេះ ត្រូវបានធ្វើឡើង បន្ទាប់ពីមានសំណើសុំដោយទទូចជាអន្តរជាតិ និងទស្សនកិច្ចរបស់លោក Christopher Hill ជាជំនួយការរដ្ឋមន្ត្រីក្រសួងការបរទេសអាមេរិកទទួលបន្ទុកកិច្ចការអាស៊ីបូព៌ា។ តាមសេចក្តីរាយការណ៍បានឲ្យដឹងថា សម្តេចនាយករដ្ឋមន្ត្រី លោកបានមានប្រសាសន៍យោងដោយចំហដល់ការដោះលែងលោក ម៉ម សូណង់ ដូ ក្នុងខែមករា ឆ្នាំ២០០៦ នេះថាជា "កាដូ" មួយជូនដល់ជំនួយការរដ្ឋមន្ត្រីក្រសួងការបរទេសអាមេរិកលោក Christopher Hill។[៦]



*បដាសមាគមអ្នកប្រជាធិបតេយ្យ ដែលនិយាយអំពីគោលដៅ ៣ យ៉ាងគឺ: ១. ពង្រឹងលទ្ធិប្រជាធិបតេយ្យក្នុងព្រះរាជាណាចក្រកម្ពុជា ២. ការពារសិទ្ធិប្រជាពល រដ្ឋតាមច្បាប់ និង ៣. ជួយប្រជាពលរដ្ឋធ្វើអត្តសញ្ញាណប័ណ្ណសម្រាប់ចូលរួមការបោះឆ្នោត។*

[៦] សូមមើល Milestones, Alex Pasternack, Time Magazine, ថ្ងៃទី ២៣ ខែមករាឆ្នាំ ២០០៦ ដែលមានក្នុងគេហទំព័រ: http://www. time.com/time /magazine /article/ 0,9171,1151841,00.html (ចូលប្រើប្រាស់បានចុងក្រោយនៅថ្ងៃទី៣ ខែសីហា ឆ្នាំ២០១២)។

## យុទ្ធនាការសុំឲ្យដោះលែងលោក ម៉ម សូណង់ដូ

ការចោទប្រកាន់ និងការចាប់ខ្លួនលោក ម៉ម សូណង់ដូ ក៏ដូចគ្នានឹងការធ្វើយុត្តិកម្មចំពោះ "គម្រោងអបគមន៍" សម្រាប់ការបណ្តេញចេញដោយហិង្សានៅថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១២ បានទទួលរងនូវការរិះគន់យ៉ាងរាលដាលភ្លាមៗ។ អង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិ ព្រមទាំងសមាគមអ្នកសារព័ត៌មាននានា បានអំពាវនាវសុំឲ្យមានការដោះលែង លោក ម៉ម សូណង់ដូជាបន្ទាន់។[៧]

នៅថ្ងៃទី២៣ ខែកក្កដា មានមនុស្សរាប់រយនាក់ បានមកជួបជុំគ្នាក្នុងពិធីបួងសួងមួយដោយសន្តិវិធីក្នុងរាជធានីភ្នំពេញ ដើម្បីធ្វើការគាំទ្រដល់លោក ម៉ម សូណង់ដូ។ ហើយនៅថ្ងៃទី២ ខែសីហា អង្គការលើកលែងទោសអន្តរជាតិបានចាត់ថ្នាក់លោក ម៉ម សូណង់ដូ ថាជាអ្នកទោសមនសិការ ដោយបានរកឃើញយ៉ាងច្បាស់ថា លោក ម៉ម សូណង់ដូ ត្រូវបានចាប់ខ្លួន និងឃុំខ្លួនក្នុងពន្ធនាគារ ដោយសារតែលោកគ្រាន់តែបានប្រើប្រាស់សិទ្ធិក្នុងការបញ្ចេញមតិយោបល់របស់គាត់ប៉ុណ្ណោះ។

នៅពេលថ្មីៗបំផុតនេះសមាគមអ្នកប្រជាធិបតេយ្យ រាយការណ៍ថាសមាគមនេះបានធ្វើញត្តិមួយ ដែលត្រូវបានដាក់ឲ្យចរាចរក្នុងប្រទេសកម្ពុជា ធ្វើការប្រមូលបានស្នាមម្រាមដៃពីប្រជាពលរដ្ឋចំនួនជាង ១១០.២២១ នាក់ ដើម្បីស្វែងរកការដោះលែងលោក ម៉ម សូណង់ដូជាបន្ទាន់។ ស្នាមម្រាមដៃត្រូវប្រមូលបានយ៉ាងច្រើន ថ្វីបើមានការរារាំងពីសំណាក់រដ្ឋាភិបាលក៏ដោយ។ នៅទូទាំងប្រទេសអង្គការលីកាដូ ប្រមូលបានព័ត៌មានយ៉ាងច្រើនដែលថា ប្រជាពលរដ្ឋត្រូវបានឃាត់ខ្លួន និងសាកសួរយកចម្លើយ ខណៈដែលញត្តិនេះត្រូវបានចែកចាយ។

---

[៧] អង្គការដែលរិះគន់ការចាប់ខ្លួនលោក ម៉ម សូណង់ដូ និងសុំអំពាវនាវឲ្យមានការដោះលែងជាបន្ទាន់រួមមាន: អង្គការឃ្លាំមើលសិទ្ធិ មនុស្ស (Human Rights Watch) អង្គការលើកលែងទោសអន្តរជាតិ ( Amnesty International) អង្គការសង្កេតការណ៍សម្រាប់ការពារ អ្នកការពារសិទ្ធិមនុស្ស (The Observatory for the Protection of Human Rights Defenders) កម្មវិធីរួមនៃសហព័ន្ធអន្តរជាតិសម្រាប់សិទ្ធិមនុស្ស (a joint programme of the International Federation for Human Rights) និងអង្គការពិភពលោកប្រឆាំងអំពើទារុណកម្ម (the World Organisation Against Torture) អង្គការសេរីភាព/សិទ្ធិលំនៅដ្ឋាន (Freedom House) អង្គការអ្នកសារព័ត៌មានគ្មានព្រំដែន (Reporters Without Borders) អង្គការមាត្រា ១៩ (ARTICLE 19) អង្គការវេទិកាអាស៊ីសម្រាប់សិទ្ធិមនុស្ស និងការអភិវឌ្ឍន៍ (Asian Forum for Human Rights and Development (FORUM-ASIA)) អង្គការសម្ព័ន្ធអ្នកសារព័ត៌មានអាស៊ីអគ្នេយ៍ (Southeast Asian Press Alliance) មជ្ឈមណ្ឌលច្បាប់ និងសម្រាប់លទ្ធិប្រជាធិបតេយ្យ (Centre for Law and Democracy) សហព័ន្ធអ្នកសារព័ត៌មានអន្តរជាតិ (International Federation of Journalists) អង្គការឃ្លាំមើលសិទ្ធិមេធាវីប្រទេសកាណាដា (Lawyers' Rights Watch Canada) និង William Nicholas Gomes, Human Rights Ambassador for Salem-News.com.

## អនុសាសន៍នានា

ដោយសារតែទំនាស់ដីធ្លីកំពុងតែបន្តកើតមានកាន់តែធ្ងន់ធ្ងរ ការការពារបណ្ដាញប្រព័ន្ធផ្សព្វផ្សាយព័ត៌មានឯករាជ្យ ដែលមានចំនួនតិចតួចកំពុងរស់រានមានជីវិត គឺវាមានសារៈសំខាន់ខ្លាំងណាស់។ តាមរដ្ឋធម្មនុញ្ញកម្ពុជា និងកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដែលប្រទេសកម្ពុជាបានផ្ដល់សច្ចាប័ន រដ្ឋាភិបាលត្រូវតែលើកកំពស់ និងការពារសិទ្ធិជាមូលដ្ឋានរបស់ប្រជាពលរដ្ឋរបស់ខ្លួន ក្នុងការបញ្ចេញមតិយោបល់និងនីតិវិធីត្រឹមត្រូវ។

ការឃុំខ្លួនលោក ម៉ម សូណង់ដូ បណ្ដោះអាសន្នរង់ចាំបើកសវនាការ ដោយគ្មានយុត្តិកម្ម និងការចោទប្រកាន់គ្មានមូលដ្ឋានទៅលើរូបលោក គឺជាការរំលោភបំពានទៅលើកាតព្វកិច្ចទាំងនេះ។ ដោយសារនៅតែមិនទាន់មានភស្តុតាងគួរឲ្យជឿជាក់នៅឡើយ លោក ម៉ម សូណង់ដូ គួរតែត្រូវបានដោះលែងជាបន្ទាន់ ហើយនឹងលើកលែងបទចោទប្រកាន់ទាំងអស់ដោយគ្មានលក្ខខណ្ឌ។

□□□